# កិច្ចព្រមព្រៀងគម្រោង

*******

## រវាង

## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## ជាមួយនឹង

## អង្គការ បេះដូងតូច

## សង្ខេបគម្រោងកម្មវិធី

- ឈ្មោះគម្រោង៖ ១.មណ្ឌលកុមារកំព្រាបេះដូងតូច
  ២.ជួយកុមារនៅក្នុងសហគមន៍
- ឈ្មោះស្ថាប័នអនុវត្តគម្រោង៖ អង្គការ បេះដូងតូច
- អាសយដ្ឋានរបស់ស្ថាប័នអនុវត្តគម្រោង៖ ផ្លូវ ៣៨០អា ភូមិទួលមាស ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល
- ទូរស័ព្ទ៖០១២ ២០៤ ៣០៨/០១២ ៤១៧ ១៧៣ អ៊ីមែល៖ tony@littlehearts.be and insithy@gmail.com
- ទីកន្លែងអនុវត្តគម្រោង៖
  ១.ផ្លូវ ៣៨០អា ភូមិទួលមាស ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល
  ២.ឃុំសិត្បូ និងឃុំក្រាំងយ៉ូវ ស្រុកល្វាឯម ខេត្តកណ្តាល
- អាសយដ្ឋានការិយាល័យធំនៅប្រទេសប៊ែលហ្សិក៖ (VZW Little Hearts- Reg nr: 811643936 Molenlei 18-2530 Boechout-Belgium)
- Tel: (32)-497-940-679, E-mail: info@littlehearts.be, Website: www.littlehearts.be
- រយៈពេលរបស់គម្រោង៖ ០៣ ឆ្នាំ
  - ចាប់ផ្តើម៖......2 1 AUG 2018......
  - បញ្ចប់៖......2 1 AUG 2021......
- ថវិកាគម្រោងសរុប៖ **៣៣៨,១០០ ដុល្លារអាមេរិក**
- អ្នកផ្តល់ថវិកាគាំទ្រគម្រោង៖

| ឈ្មោះស្ថាប័នផ្តល់ថវិកា | ទឹកប្រាក់(ដុល្លារអាមេរិក) |
|---|---|
| La-On | ៣០,០០០ |
| Belgian Heart Bikers | ៣០,០០០ |
| Recoding | ៣០,០០០ |
| Huot Handel Martens | ៦០,០០០ |
| សប្បុរសជនក្រៅប្រទេស | ១៨៨,១០០ |
| សរុប | ៣៣៨,១០០ |

- គណនីប្រើប្រាស់ថវិកាខាងលើនៅក្នុងប្រទេសកម្ពុជា៖ ធនាគារANZ Royal Bank (Cambodia) ឈ្មោះគណនី LITTLE HEARTS ORGANIZATION លេខគណនី 2025445 ។
- ប្រភពថវិកាដែលបានផ្តល់ខាងលើទាំងនេះត្រូវតែជាថវិកា ជួយដល់ក្រុមគោលដៅមនុស្សធម៌ សុទ្ធសាធគ្មានការពាក់ព័ន្ធទៅនឹងកិច្ចការយោធា នយោបាយ ឬសាសនាឡើយ។
- ចំនួនបុគ្គលិកបរទេស ៖ ១ នាក់ (ប្រុស)
- ចំនួនបុគ្គលិកខ្មែរ ៖ ៨នាក់ (ស្រី ៤នាក់)

## គោលដៅកិច្ចសហប្រតិបត្តិការ

- ធ្វើឲ្យស្ថានភាពរស់នៅប្រចាំថ្ងៃរបស់កុមារ ដែលកំពុងស្នាក់នៅក្នុងមណ្ឌលកុមារកំព្រាបេះដូងតូច កាន់តែប្រសើរឡើង
- ផ្តល់ការសិក្សាភាសាអង់គ្លេសឥតគិតថ្លៃដល់កុមារក្នុងសហគមន៍
- ផ្តល់ការឧបត្ថម្ភកុមារចំនួន៧គ្រួសារ ក្រោយពេលធ្វើសមាហរណកម្មទៅគ្រួសារវិញ។

## ពណ៌នាគម្រោងកម្មវិធី

គម្រោងនេះបង្កើតឡើងបន្ទាប់ពីពិនិត្យឃើញថា មានកុមាររងគ្រោះ និងងាយរងគ្រោះ មិនទាន់ទទួលបានការរស់នៅ ការសិក្សា និងការថែទាំសុខភាពសមរម្យ។

គម្រោងនេះអនុវត្តនៅភូមិទួលមាស ឃុំអរិយក្សត្រ ស្រុកល្វាឯម ឃុំសិត្បូ និងឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល។

ផលប្រយោជន៍ដែលទទួលបានពីគម្រោងនេះរួមមាន៖

ក-ធ្វើឲ្យប្រសើរឡើងនូវស្ថានភាពរស់នៅរបស់កុមារ ក្នុងមណ្ឌលកុមារកំព្រាបេះដូងតូច៖

- ទទួលបានការស្នាក់នៅ ហូបចុក សំលៀកបំពាក់ សម្ភារសិក្សា សម្ភារប្រើប្រាស់ និងការថែទាំសុខភាព
- ទទួលបានការអប់រំប្រកបដោយគុណភាពពីកម្រិតមត្តេយ្យដល់មហាវិទ្យាល័យ
- បានចូលរួមនិងដឹកនាំល្បែងកំសាន្តផ្នែកអប់រំ ដើម្បីអភិវឌ្ឍផ្នែកបញ្ញា
- ទទួលបានការលើកស្ទួយសិទ្ធិកុមារ ជាពិសេសសិទ្ធិក្នុងការបញ្ចេញមតិ
- ទទួលបានការសិក្សាបំប៉នបន្ថែម ដូចជាភាសាខ្មែរ គណិតវិទ្យា ពីកម្រិតបឋមដល់ថ្នាក់វិទ្យាល័យ ព្រមទាំងភាសាអង់គ្លេស និងកុំព្យូទ័រ។
- ទទួលបានការលេងល្បែងថាមពល ល្បែងប្រជាប្រិយ កីឡា និងសិល្បៈ
- ទទួលបានដំណើរកំសាន្ត និងទស្សនកិច្ចសិក្សាក្នុងស្រុក

ខ- ធ្វើឲ្យប្រសើរឡើងនូវស្ថានភាពរស់នៅរបស់កុមារក្នុងសហគមន៍៖

- ទទួលបានអង្ករចំនួន៥០ គីឡូក្រាម មីចំនួន១កេះ ក្នុងរយៈពេលពីរខែម្តង
- សំលៀកបំពាក់ សម្ភារប្រើប្រាស់ ០១ឆ្នាំម្តង និងសេវាថែទាំសុខភាព
- សម្ភារសិក្សា និងការសិក្សាភាសាអង់គ្លេស

| ល.រ | ក្រុមគោលដៅ | ចំនួន | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ស្រី | ប្រុស | សរុប | |
| ១ | កុមារក្នុងមណ្ឌល | ១៨ | ២០ | ៣៨ | |
| ២ | កុមារមកពីសហគមន៍ | ៤២ | ៣១ | ៧៣ | |
| ៣ | កុមារក្រោយសមាហរណកម្ម | ០៤ | ០៥ | ០៩ | |
| សរុប | | ៦៣ | ៥៥ | ១១៨ | |

**លក្ខខណ្ឌលម្អិត**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**និង**

**អង្គការបេះដូងតូច**

**បានព្រមព្រៀងដូចខាងក្រោមនេះ**

**មាត្រា ១**

**លក្ខខណ្ឌទូទៅនៃកិច្ចព្រមព្រៀង**

១.១ កិច្ចព្រមព្រៀងនេះ គឺធ្វើឡើងក្រោមកិច្ចសហប្រតិបត្តិការរវាង**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និង **អង្គការបេះដូងតូច** ទាំងការអនុវត្ត និងការវាយតម្លៃលើសកម្មភាពទាំងមូលរបស់គម្រោង ដើម្បីឲ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

១.២ រាល់ការអនុវត្តកម្មវិធីត្រូវបានពិភាក្សាជាមួយនិងមន្ទីរជំនាញថ្នាក់រាជធានីខេត្ត ដែលមានការពាក់ព័ន្ធ។

១.៣ រាល់ការសាងសង់សំណង់ណាមួយ ត្រូវធ្វើការពិភាក្សាល្អិតល្អន់ជាមួយ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ជាមុនសិនទើបអាចដំណើរការបាន ។ រាល់គម្រោង និងប្លង់សាងសង់រួមទាំងក្បាច់រចនា ត្រូវធ្វើឡើងស្របតាមបទដ្ឋានជាតិ។

១.៤ កាលបរិច្ឆេទនៃគម្រោងចាប់ផ្តើមនៅថ្ងៃទី........21 AUG 2018........
និងបញ្ចប់ទៅវិញថ្ងៃទី........21 AUG 2021........។

១.៥ ក្នុងភាពជាដៃគូការងារ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និង **អង្គការបេះដូងតូច** បានឯកភាពគ្នាថានឹងធ្វើការពិនិត្យឡើងវិញលើគម្រោងនេះយ៉ាងតិច០៣ខែ មុនកាលបរិច្ឆេទបញ្ចប់នៃគម្រោង។ ក្រោយពីបានពិនិត្យ និងពិភាក្សាគ្នារួចហើយសេចក្តីសម្រេចរួមគ្នានឹងត្រូវធ្វើឡើង ថាតើត្រូវបញ្ចប់គម្រោងតាមពេលកំណត់ឬក៏ស្វែងរកកិច្ចបន្តគម្រោងនេះមួយរយៈបន្ថែមទៀត។

១.៦ កិច្ចព្រមព្រៀងនេះត្រូវបានប្រើប្រាស់ជាផ្លូវការដោយ**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និង**អង្គការបេះដូងតូច** សម្រាប់ជាមូលដ្ឋានក្នុងការធ្វើសហប្រតិបត្តិការ។

១.៧ **អង្គការបេះដូងតូច** ត្រូវគោរពតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាដែលបានអនុម័តឲ្យប្រើប្រាស់នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ។

## មាត្រា ២
## អង្គការបេះដូងតូចបានព្រមព្រៀង៖

២.១ អនុវត្តការងារដើម្បីសម្រេចនូវទិសដៅរបស់គម្រោងជាក់លាក់ដូចខាងក្រោម៖

- ធ្វើឲ្យស្ថានភាពរស់នៅប្រចាំថ្ងៃរបស់កុមារ ដែលកំពុងស្នាក់នៅក្នុងមណ្ឌលកុមារកំព្រាបេះដូងតូចកាន់តែប្រសើរឡើង
- ផ្តល់ការសិក្សាភាសាអង់គ្លេសឥតគិតថ្លៃដល់កុមារក្នុងសហគមន៍
- ផ្តល់ការឧបត្ថម្ភកុមារចំនួន៧គ្រួសារ ក្រោយពេលធ្វើសមាហរណកម្មទៅគ្រួសារវិញ។
- សហការឲ្យបានជិតស្និទ្ធជានិច្ចជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

២.២ សហការយ៉ាងជិតស្និទ្ធជាមួយ**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ដែលជាដៃគូការងារដើម្បីទទួលបានលទ្ធផលកម្រិតអតិបរមាក្នុងការផ្ទេរនិងពង្រឹងជំនាញបច្ចេកទេស។

២.៣ រាល់ការបោះពុម្ព ឬឯកសារទាំងឡាយណាដែលបានពីសមិទ្ធផលរបស់គម្រោងនេះ ត្រូវដាក់ជូនក្រសួងផ្តល់យោបល់រួចហើយនឹងត្រូវចាត់ទុកជាសម្បត្តិរួមគ្នារបស់**អង្គការបេះដូងតូច**និង **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ។

២.៤ ចូលរួមឲ្យបានទៀងទាត់រាល់កិច្ចប្រជុំនីមួយៗតាមការអញ្ជើញរបស់ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ដើម្បីសម្របសម្រួលសកម្មភាពរបស់គម្រោងដែលកំពុងដំណើរការព្រមទាំងធ្វើការផ្លាស់ប្តូរព័ត៌មានគ្នាដើម្បីឈានទៅសម្រេចជោគជ័យតាមទិសដៅរបស់គម្រោង។

២.៥ ផ្តល់របាយការណ៍ប្រចាំត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ជូន**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**(នៅនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក)។
របាយការណ៍ដូចគ្នានេះត្រូវចម្លងជូន៖

- នាយកដ្ឋានសុខុមាលភាពកុមារ
- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តកណ្តាល ដែលអង្គការកំពុងធ្វើសកម្មភាព។

២.៦ ក្នុងរយៈពេល១ឆ្នាំ បន្ទាប់ពីក្រសួងនិងអង្គការបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាផ្លូវការរួចមកបើ **អង្គការបេះដូងតូច** ពុំបានធ្វើរបាយការណ៍ដូចមានចែងនៅក្នុងមាត្រា២.៥ ក្រសួង កំណត់ថា **អង្គការបេះដូងតូច** ពុំបានអនុវត្តគម្រោងកម្មវិធីហើយ ត្រូវចាត់ទុកជាមោឃៈ និងអស់សុពលភាពដោយស្វ័យប្រវត្តិ។

២.៧ ទទួល ឬបង្កលក្ខណៈដល់មន្ត្រីរបស់**ក្រសួង និងមន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** រាជធានី ខេត្ត និងការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើការក្នុងគម្រោងកម្មវិធីដោយយោងលើប្រភេទគម្រោងកម្មវិធីដូចជាមធ្យោបាយធ្វើដំណើរកិច្ចសម្របសម្រួលទំនាក់ទំនងការងារ។

២.៨ ជូនដំណឹងមក**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ជាលាយលក្ខណ៍អក្សរនៅពេលដែលអង្គការផ្លាស់ប្តូរអាសយដ្ឋាន ប្រធានអង្គការ គម្រោងកម្មវិធី លេខទូរស័ព្ទ និងទូរសារទំនាក់ទំនង។ ចំពោះករណីមានការនាំចូលឧបករណ៍ និងសម្ភារដែលយកមកប្រើប្រាស់

សម្រាប់សកម្មភាពគម្រោង**អង្គការកុមារបេះដូងតូច** ត្រូវជូនដំណឹងមក**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** តាមពេលវេលាសមស្របមុនពេលដែលឧបករណ៍ និងសម្ភារនោះគ្រោងនាំចូលមកដល់ទឹកដីព្រះរាជាណាចក្រកម្ពុជា។

២.៩ គម្រោងថវិកាដែលបានអនុម័តត្រូវប្រើប្រាស់ឲ្យមានប្រសិទ្ធភាពតាមទិសដៅដូចបានកំណត់។ (សរុបចំណាយមិនផ្ទាល់មិនត្រូវលើស២៥% នៃចំណាយសរុប)

| **គម្រោងចំណាយ** | **សីហា-២០១៨** | **២០១៩** | **២០២០-សីហា២០២១** | **ទឹកប្រាក់សរុប (ដុល្លារអាមេរិក)** |
|---|---|---|---|---|
| ចំណាយលើប្រាក់ខែបុគ្គលិកខ្មែរ | ២៥,០០០ | ២៥,០០០ | ២៥,០០០ | ៧៥,០០០ |
| ចំណាយសម្រាប់ការិយាល័យ និងការងាររដ្ឋបាលផ្សេងៗ | ១,២០០ | ១,២០០ | ១,២០០ | ៣,៦០០ |
| សរុបចំណាយមិនផ្ទាល់ | ២៦,២០០ | ២៦,២០០ | ២៦,២០០ | ៧៨,៦០០ |
| ចំណាយលើការបណ្តុះបណ្តាលរបាំភ្លេង គំនូរហត្ថកម្មនិងថ្នាក់បំប៉ន | ១,២០០ | ១,២០០ | ១,២០០ | ៣,៦០០ |
| ចំណាយលើសិក្ខាសាលាដល់កុមារនិងបុគ្គលិក ការផ្តត់ផ្គង់សម្ភារបច្ចេកទេសសិក្សា | ១,៨០០ | ១,៨០០ | ១,៨០០ | ៥,៤០០ |
| ចំណាយលើការធ្វើដំណើរនិងដឹកជញ្ជូន ជួសជុល ថែទាំ | ៧,៥០០ | ៧,៥០០ | ៧,៥០០ | ២២,៥០០ |
| ចំណាយលើការសង្គ្រោះបឋម និងការព្យាបាលជំងឺដល់កុមារ | ១,២០០ | ១,២០០ | ១,២០០ | ៣,៦០០ |
| ចំណាយលើការសិក្សាបន្ថែមគ្រប់កំរិតនឹងថ្នាក់ត្រៀមប្រឡង | ១០,០០០ | ១០,០០០ | ១០,០០០ | ៣០,០០០ |
| ចំណាយលើអាហារហូបចុក | ៣០,០០០ | ៣០,០០០ | ៣០,០០០ | ៩០,០០០ |
| ចំណាយលើថ្នាំពេទ្យ ការសិក្សា សម្ភារៈ និងសំលៀកបំពាក់ | ១,៨០០ | ១,៨០០ | ១,៨០០ | ៥,៤០០ |
| ថ្លៃសិក្សាជំនាញ និងមហាវិទ្យាល័យ | ៣,៦០០ | ៣,៦០០ | ៣,៦០០ | ១០,៨០០ |
| ចំណាយលើការបណ្តុះបណ្តាលភាសាអង់គ្លេស និង កុំព្យូទ័រ | ២៧,៦០០ | ២៧,៦០០ | ២៧,៦០០ | ៨២,៨០០ |
| ចំណាយលើអង្ករ មី ដល់គ្រួសារកុមារ | ១,២០០ | ១,២០០ | ១,២០០ | ៣,៦០០ |
| ប្រាក់កម្ចីសំរាប់មុខរបរ | ៦០០ | ៦០០ | ៦០០ | ១,៨០០ |
| **សរុបចំណាយផ្ទាល់** | ៨៦,៥០០ | ៨៦,៥០០ | ៨៦,៥០០ | ២៥៩,៥០០ |
| **ចំណាយសសរុបគម្រោង** | ១១២,៧០០ | ១១២,៧០០ | ១១២,៧០០ | ៣៣៨,១០០ |

២.១០ ថវិការបស់**អង្គការបេះដូងតូច** ជាជំនួយសម្រាប់កម្មវិធីមនុស្សធម៌សុទ្ធសាធ ហើយអង្គការនេះនឹងមិនប្រើប្រាស់ជំនួយនេះក្នុងគោលបំណងនយោបាយ សាសនា ឬយោធាឡើយ។

២.១១ គោរពតាមច្បាប់ អនុក្រឹត្យ ប្រកាស បទដ្ឋាន គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាអាទិ៍ៈ

- ព្រះរាជក្រមលេខនស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ស្តីពីការប្រកាសឲ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- អនុក្រឹត្យលេខ៣៤.អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ស្តីពីការប្រគល់មុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋឲ្យទៅរដ្ឋបាលរាជធានី-ខេត្តការប្រគល់មុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលឲ្យទៅរដ្ឋបាលរាជធានីក្រុង ស្រុក និងការប្រគល់មុខងារគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ ទៅឲ្យរដ្ឋបាលរាជធានីរដ្ឋបាលក្រុង និងរដ្ឋបាលឃុំ
- អនុក្រឹត្យលេខ១១៩អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ
- ប្រកាសលេខ៣០៨ស.អ.យ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៦ ស្តីពីលក្ខខណ្ឌ និងទម្រង់បែបបទនៃការស្នើសុំការ អនុញ្ញាតបង្កើតមណ្ឌលថែទាំកុមារ
- គោលនយោបាយលេខ៩០៧ ស.អ.យ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦ស្តីពីការថែទាំជំនួសចំពោះកុមារ
- ប្រកាសលេខ២១៧ ស.អ.យ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦ ស្តីពីការដាក់អោយអនុវត្តគោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារ
- ប្រកាសលេខ៦១៦ស.អ.យ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល
- ប្រកាសលេខ១៩៨ ស.អ.យ ចុះថ្ងៃទី ១១ ខែមិនា ឆ្នាំ ២០០៨ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍
- ប្រកាសលេខ២២៨០ ស.អ.យ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ ស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ
- ប្រកាសលេខ១៨០១ ស.អ.យ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការទទួលស្គាល់គុណវុឌ្ឍិនៃអង្គការសុវត្ថិភាពកុមារ

២.១២ សហការជាមួយ**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** លើកម្មវិធីបង្រួបបង្រួមគ្រួសារដើម្បីបំពេញកិច្ចការឲ្យបានគ្រប់ជ្រុងជ្រោយ និងប្រកបដោយការទទួលខុសត្រូវ។ អង្គការត្រូវធ្វើការវាយតម្លៃមួយឆ្នាំម្តង តើលទ្ធភាពធ្វើសមាហរណកម្មឲ្យកុមារទៅរស់នៅជាមួយគ្រួសារសាច់ញាតិ ឪពុកម្តាយធម៌នៅក្នុងសហគមន៍ ។ ក្នុងរយៈពេល២ឆ្នាំដំបូង បុគ្គលិកអង្គការត្រូវចុះតាមដានកុមារដែលបានធ្វើសមាហរណកម្មជារៀងរាល់ត្រីមាស ។ ចាប់ពីឆ្នាំ២០១៨ ការទទួលទុកដាក់កុមារត្រូវបំពេញទម្រង់គ្រប់គ្រងករណីថ្មី និងគំរូលិខិតបទដ្ឋានឲ្យស្របតាមការអនុវត្តប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ។

២.១៣ អនុញ្ញាតឲ្យមន្ត្រី**ក្រសួង និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** រាជធានី ខេត្ត ចុះត្រួតពិនិត្យវាយតម្លៃ និងតាមដានគម្រោងកម្មវិធីរបស់អង្គការ។

២.១៤ ផ្ដល់ច្បាប់ថតចម្លងកិច្ចព្រមព្រៀងនេះទៅនាយកដ្ឋានជំនាញ និង**មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** រាជធានី ខេត្ត ដែលអង្គការធ្វើសកម្មភាពក្រោយពីកិច្ចព្រមព្រៀងនេះចូលជាធរមាន។

## មាត្រា ៣
## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ព្រមព្រៀង៖

៣.១ ចាត់តាំងបុគ្គលិកដែលមានលក្ខណៈសម្បត្តិ និងសមត្ថភាពសមស្រប (ថ្នាក់ក្រសួង មន្ទីរ ក្រុង ស្រុក ខណ្ឌ) ឲ្យបំពេញការងារជាមួយ **អង្គការបេះដូងតូច** ដើម្បីឲ្យសកម្មភាពគម្រោងអនុវត្តទៅមានប្រសិទ្ធិភាព និងទាន់ពេលវេលា។

៣.២ អនុញ្ញាតឲ្យ **អង្គការបេះដូងតូច** អាចជួលបុគ្គលិកកម្ពុជាធ្វើការបានដោយអនុលោមតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

៣.៣ សម្របសម្រួលក្នុងករណីចាំបាច់ដល់ការសុំទិដ្ឋាការឲ្យបុគ្គលិក និងទីប្រឹក្សារបស់អង្គការដែលចូលរួមក្នុងសកម្មភាពគម្រោងដែលត្រូវបានទទួលស្គាល់តាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ។

៣.៤ សម្របសម្រួលតាមករណីសមស្របដើម្បីស្នើសុំពន្ធ និងអាករជាបន្ទុករបស់រាជរដ្ឋាភិបាលកម្ពុជាដល់ឧបករណ៍ និងសម្ភារដែលយកមកប្រើប្រាស់គាំទ្រឲ្យសកម្មភាពគម្រោង។

៣.៥ ជំរុញឲ្យមន្ទីរជំនាញរាជធានី ខេត្ត ឬក្រុង ស្រុក ខ័ណ្ឌ ធ្វើការប្រាស្រ័យទាក់ទងឲ្យបានជិតស្និទ្ធជាមួយអង្គការ ដើម្បីជួយកសាងផែនការគ្រប់គ្រង និងដោះស្រាយបញ្ហា។

៣.៦ រាល់សំណើផ្សេងៗពីអង្គការ នឹងត្រូវបានផ្ដល់ចម្លើយពីក្រសួងវិញជាលាយលក្ខណ៍អក្សរ។

៣.៧ អនុញ្ញាត**អង្គការបេះដូងតូច** ពិភាក្សាជាមួយនាយកដ្ឋានជំនាញ ឬអង្គភាពពាក់ព័ន្ធរបស់ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** លើកិច្ចដំណើរការ ដើម្បីសម្រេចបាននូវការព្រមព្រៀងផ្សេងៗស្របតាមលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្នើសុំសេចក្ដីសម្រេចពីរដ្ឋមន្ត្រី **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ។

## មាត្រា ៤
## លក្ខខណ្ឌរួម

៤.១ ប្រធាន**អង្គការបេះដូងតូច** ត្រូវជ្រើសតាំងជាតំណាងស្របច្បាប់ដោយ **អង្គការបេះដូងតូច** នឹងត្រូវផ្ដល់សិទ្ធិជាតំណាងអង្គការនេះដើម្បីធ្វើការជាមួយ**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**។

៤.២ វិសោធនកម្មជាលាយលក្ខណ៍អក្សរនៃកិច្ចព្រមព្រៀងនេះ អាចធ្វើទៅបានដោយមានការព្រមព្រៀងគ្នាទៅវិញទៅមក និងចុះហត្ថលេខាដោយភាគីទាំងពីរបន្ទាប់ពីបានពិចារណារួចហើយ។

៤.៣ កិច្ចព្រមព្រៀងនេះ អាចត្រូវបានបញ្ចប់ក្នុងស្ថានភាពបន្ទាន់តាមការសម្រេចរួមគ្នាមួយរវាងតំណាង **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និង **អង្គការបេះដូងតូច** ក្រោយពីបានពិគ្រោះ និងពិចារណារួចរាល់ហើយ។

៤.៤ **អង្គការបេះដូងតូច** មានសិទ្ធិបញ្ឈប់សកម្មភាពភ្លាមលើកិច្ចព្រមព្រៀងនេះក្រោយពីបានពិភាក្សាជាមួយ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ប្រសិនជាពិនិត្យឃើញថាគ្មានកិច្ចសហប្រតិបត្តិការគ្រប់គ្រាន់សម្រាប់ការអនុវត្តគម្រោងឲ្យមានប្រសិទ្ធភាព ឬសន្តិសុខនៃបុគ្គលិក ឬទ្រព្យសម្បត្តិរបស់ខ្លួនស្ថិតក្នុងប្រធានស័ក្ត។

៤.៥ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** មានសិទ្ធិបញ្ចប់កិច្ចព្រមព្រៀងនេះដោយចេញលិខិតរបស់ក្រសួងជាផ្លូវការ ប្រសិនបើការអនុវត្តដំណោះស្រាយដូចក្នុងមាត្រា៤.២ ៤.៣ និង៤.៤ នៃកិច្ចព្រមព្រៀងនេះមិនអាចសម្រេចបាន ឬមានគោលការណ៍ថ្មីតម្រូវ។

៤.៦ បន្ទាប់ពីបានពិភាក្សាជាមួយ **អង្គការកុមារបេះដូងតូច** រួច **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** នឹងស្នើសុំឲ្យអង្គការបញ្ឈប់ការងារចំពោះបុគ្គលិក ណាដែលត្រូវបានវិនិច្ឆ័យថាធ្វើឲ្យខូចកិត្តិយសក្រសួង ឬបានប្រព្រឹត្តខុសនឹងក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួនហើយ**អង្គការបេះដូងតូច** ត្រូវតែអនុវត្តតាមដំណើរការនេះ។

៤.៧ ក្រោយពីបានពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធ**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**មានសិទ្ធិបញ្ឈប់កិច្ចព្រមព្រៀងនេះប្រសិនបើតំណាងផ្លូវការរបស់**អង្គការបេះដូងតូច** ត្រូវបានគេវិនិច្ឆ័យឃើញថាមិនបានបំពេញតាមមាត្រា២នៃកិច្ចព្រមព្រៀងនេះ។

៤.៨ កិច្ចព្រមព្រៀងនេះអនុញ្ញាតឲ្យអង្គការបន្តកិច្ចសហប្រតិបត្តិការជាមួយ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ក្នុងថេរវេលាដូចមានចែង ក្នុងថេរវេលាដូចមាន ចែងក្នុងចំណុច១.៤។ចំពោះការគ្រប់គ្រងកុមារ អង្គការត្រូវអនុវត្តតាមបទដ្ឋាននានាពាក់ព័ន្ធទៅនឹងកុមារដែល**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានផ្សព្វផ្សាយឲ្យអនុវត្ត ហើយការទទួលខុសត្រូវស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់នាយកដ្ឋានសុខុមាលភាពកុមារ របស់**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ដូចនេះតម្រូវឲ្យអង្គការត្រូវបំពេញបែបបទ និងលក្ខខណ្ឌនានាដែលមានបញ្ជាក់ពីការគ្រប់គ្រងរបស់នាយកដ្ឋានសុខុមាលភាពកុមារ។

៤.៩ ប្រសិនបើ **អង្គការបេះដូងតូច** មិនគោរពតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** អាចបញ្ឈប់កិច្ចព្រមព្រៀងនេះបន្ទាប់ពីជូនព័ត៌មានដល់សាមីអង្គការនោះរួចមក។

៤.១០ កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា ហើយមានសុពលភាពរហូតដល់ថ្ងៃបញ្ចប់គម្រោង។

កិច្ចព្រមព្រៀងនេះ *ត្រូវបានរៀបចំឡើងដោយឥតកែប្រែជាភាសាខ្មែរ ។*

បានចុះហត្ថលេខានៅថ្ងៃ...ពុធ ៥កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញថ្ងៃទី...២១.......ខែ.....មីនា........ឆ្នាំ២០១៨

**ហត្ថលេខី**

| | |
|---|---|
| **តំណាង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | **តំណាង អង្គការបេះដូងតូច** |
| ឈ្មោះ៖ **ហាច ហ៊ាន** | ឈ្មោះ៖ **តូនី ឡៅរ៉ាត** |
| តួនាទី៖ **អគ្គនាយកកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ** | តួនាទី៖ **នាយកអង្គការ** |